នៅក្នុងការសម្ភាសនេះលោកពូបានរៀបរាប់ប្រាប់ពីជីវិតដ៏សែនលំបាក ដែលគាត់បានមាននៅក្នុងរបបសង្គ្រាម គឺវេទនាពិបាករងទុក្ខនូវការស្រេកឃ្លានយ៉ាងខ្លាំង ហើយដល់ថ្នាក់ទៅលួចស្រូវពេលយប់ដើម្បីទុកហូបព្រោះការហូបវាមិនគ្រប់គ្រាន់តែម្តង ហើយពេលជិតបែកកងទ័ពវៀតណាមចូលមក គឺគាត់និងគ្រួសារត្រូវរត់គេចទៅច្រើនកន្លែង ព្រោះប្រទេសរឹករវខ្លាំងមានការបាញ់គ្នាកក្រើកពេញ។ បន្ទាប់ពីបែកសង្គ្រាមមកពូបានរៀនបន្ត ហើយបានចូលធ្វើទ័ពដោយសារចង់សងសឹកសម្រាប់បងប្អូនដោយសារពួកប៉ុលពត បានសម្លាប់បងប្អូនសាច់ញាតិ និង បងប្អូនខ្មែរជាច្រើន នេះគឺជាកំហឹងហើយពូបានសម្លាប់ពួកប៉ុល ពត គាត់ថាមិនតិចជាង៥០នាក់ ។ លោកពូក៏ធ្លាប់បានរៀនពេទ្យផងដែរ។ លោកពូបានឈប់ធ្វើទ័ពហើយបានធ្វើការលីសែងនៅផ្សារច្បារអំពៅក៏បានជួបប្រពន្ធហើយរៀបការមានកូនចៅ ហើយឥឡូវជីវិតរបស់លោកពូក៏មិនសូវស្រួលដែរ ដោយសារជីវភាពនិងជម្ងឺគឺលំបាក ។

# ការសម្ភាសជាលើកទី២របស់លោកពូ ព្រំ សំអូន

*កៈ អ្នកសម្ភាសឈ្មោះ ញ៉ែម សុគន្ធា ខៈ អ្នកត្រូវគេសម្ភាសឈ្មោះព្រំ សំអូន*

កៈ ជាដំបូងនាងខ្ញុំសូមថ្លែងអំណរគុណដល់លោកពូ ដែលឱ្យខ្ញុំសម្ភាសអំពីជីវប្រវត្តិរបស់លោកពូនាងខ្ញុំឈ្មោះញ៉ែម សុគន្ធា ជាអ្នកសម្ភាសអំពីជីវិតរបស់លោកពូនៅក្នុងថ្ងៃនេះ ហើយពួកយើងសម្ភាសនៅក្នុងខែមិនាឆ្នាំ២០១៨។ ការសម្ភាសមានទីតាំងនៅក្នុងភូមិព្រែកហូរខាងលិចសង្កាត់ព្រែកហូរ ក្រុងតាខ្មៅ ខេត្តកណ្តាល ប្រទេសកម្ពុជា។ ហើយដោយសារពួកយើងបានសម្ភាសពូអំពីជីវប្រវត្តិរបស់ដូនតារបស់ពូ កាលពីមុនមកហើយ ប៉ុន្តែដោយសារនៅជីវប្រវត្តិខ្លះៗទៀត នៅដំណើរជីវប្រវត្តិរបស់លោកពូនៅតាំងពីក្មេង ពីក្មេងរហូតដល់ធំថាតើលោកពូបានជួបរឿងអីគេខ្លះអញ្ចឹងពួកយើងនឹងចាប់ផ្តើមសម្ភាសអំពីជីវប្រវត្តិរបស់លោកពូដូចតទៅ។ អញ្ចឹងលោកពូសូមប្រាប់ឈ្មោះពេញរបស់លោកពុម្តងទៀតហ៉ា។

ខៈ បានខ្ញុំឈ្មោះព្រំ សំអូន។

កៈ អញ្ចឹងលោកពូសម្រាប់ការសិក្សារបស់លោកពូហ៉ា ពូរៀនបានថ្នាក់ទីប៉ុន្មានដែរ?

ខ៖ ខ្ញុំរៀនបានត្រឹមឌីផ្លូម។

ក៖ ចាស! អញ្ចឹងឌីផ្លូមថ្នាក់ទី៩ហើពូពេលហ្នឹងហើក៏អត់ទេ?

ខ៖ បាទ! អត់ទេសម័យហ្នឹងមិនមែនដូចសម័យឥឡូវនោះទេ។ កាលពីយើងរៀនតាំងពី៧៩ (១៩៧៩) មកហ្នឹងណាំ អើខ្ញុំរៀនបន្តកាលពីសម័យលន់នល់។

ក៖ ហ៊ឺៗ!

ខ៖ ក្រោយមកសម័យយើង៧៩(១៩៧៩) សម័យរដ្ឋកម្ពុជានេះខ្ញុំរៀនបានត្រឹមថ្នាក់៨៤ (១៩៨៤)។

ក៖ ត្រឹមឆ្នាំ៨៤ (១៩៨៤)។

ខ៖ ឆ្នាំ៨៤(១៩៨៤) ខ្ញុំយក ខ្ញុំយកសញ្ញាប័ត្រឌីផ្លូមបាន ។

ក៖ ហើយថីបានពូបានឈប់រៀន ហើក៏ចប់ថ្នាក់ត្រឹមហ្នឹងឬក៏ម៉េច?

ខ៖ ការពិតស្រុកខ្មែរយើងពីជំនាន់ ហ្នឹងបញ្ចប់ថ្នាក់ត្រឹមទី១២ ។

ក៖ ដូចឥឡូវហ្នឹងដែរ?

ខ៖ បាទ!

ក៖ ហើយគ្រូ គ្រូសុទ្ធតែសល់ពីជំនាន់សង្គ្រាមដែរហ្នឹងមកហើយមែនទេពូ?

ខ៖ បាទ! សុទ្ធតែសម័យហ្នឹងទាំងអស់។

ក៖ អើ! តើគេធ្វើម៉េចបានរើសគ្រូបានទៅដោយសារ ភាគច្រើនអ្នកចេះដឹងស្លាប់អស់ហើយហ្នឹងពូ។

ខ៖ គេដឹងថាសម័យចាយលុយដែរហ្នឹង ប៉ុន្តែសម័យហ្នឹងចាយលុយយួនមិនទាន់បានចាយលុយខ្មែរទេ ដល់មក៨១ ៨១(១៩៨១-១៩៨២) ហើយបានប្រកាសឱ្យចាយលុយខ្មែរ។

ក៖ ហ្អ៎! ចាស! ដោយសារដំបូងវាអត់ដឹងរៀបចំប្រទេសម៉េចណោះពូណោះ?

ខ៖ បាទៗ!

ក៖ នៅក្នុងសភាពមួយដែលពិបាករឹកររនៅឡើយដែរហ្នឹង ដោយសារងើបពីសង្គ្រាមអីចាប់ផ្តើមថ្មីទាំងអស់ហ្នឹងពូណោះ?

ខ៖ បាទ! រៀបចំរដ្ឋាភិបាលយើងល្អដែរ បានដឹកនាំប្រទេសបានល្អតាំងពីសម័យអត់ឃ្លាន រហូតដល់សម័យចាយដល់ដុល្លារទៅហើយនិងនិយាយអញ្ចេះវិញ។

ក៖ ចាស! អញ្ចឹងពូរៀនពូរៀននៅសាលាបឋមសិក្សាអីគេឈ្មោះ? បឋមសិក្សាណាវិញ?

ខ៖ ខ្ញុំរៀននៅសាលាចិនអ្នកលឿង។

ក៖ ចាស!

ខ៖ ពីព្រោះអាផ្លាកហ្នឹងពីដើមគេដាក់សាលាចិន តែដល់ពេល៧៩ហ្នឹង (១៩៧៩) ទៅចូលរៀនហ្នឹងរៀននៅក្នុងសាលាចិនប៉ុន្តែរៀនជាភាសាខ្មែរទេ។

ក៖ ប៉ុន្តែសាលាហ្នឹងឈ្មោះអីអត់ដឹងទេ តែគ្រាន់តែដាក់ផ្លាកសាលាចិនអ៊ីចឹងទៅពូណោះ?

ខ៖ សាលាហ្នឹងនៅឃុំព្រែកខ្សាយ។

ក៖ ចាស!

ខ៖ ប៉ុន្តែគ្រាន់តែគេដាក់ផ្លាកឃីហោរហ្នឹងគេដាក់សាលាចិន។

ក៖ ចាស!

ខ៖ ហ្នឹងខ្ញុំរៀននៅហ្នឹង។

ក៖ ចាស!

ខ៖ ខ្ញុំរៀនបានត្រឹម៨៣(១៩៨៣ )៨២(១៩៨២) រៀនបានមកត្រឹម៨២(១៩៨២) ហើយក៏ឪពុកម្តាយផ្លាស់មកនៅភ្នំពេញនេះ ហើយមករៀននៅក្នុងភ្នំពេញនេះបានថ្នាក់ឌីផ្លូមនៅក្នុងភ្នំពេញនេះ។

ក៖ សាលាណាវិញពូរៀន? ច្បារអំពៅហី?

ខ៖ រៀននៅសាលាច្បារអំពៅ ច្បារអំពៅទី១។

ក៖ ហ្អ៎! អញ្ចឹងគេបង្កើតតាំងពីបែកមកណោះពូហោ៎?

ខ៖ បាទ!

ក៖ ចាស!

ខ៖ មកធ្វើសាលានៅហ្នឹងមកឱ្យកូនក្មេងកូនសិស្សរៀន។

ក៖ អញ្ចឹងពូសម្រាប់ពេលពូរៀនហ៎ា ពូមានក្តីប្រាថ្នាចង់ធ្វើអីគេដែរ?

ខ៖ កាលពីជំនាន់ខ្ញុំរៀនហ្នឹង ខ្ញុំមានប្រាថ្នាមួយ សូមសងសឹកជាមួយនឹងខ្មែរក្រហម ពីព្រោះអីបានខ្ញុំគប់អីចឹង  ពីព្រោះប្អូនៗអត់ឃ្លានស្លាប់ហើយបងប្អូនជីដូនមួយជីទួតមួយអីសុទ្ធ តែយកទៅកាប់សម្លាប់ទាំងអស់។ បាទ! ដល់អញ្ចឹងការឈឺចាប់របស់ខ្ញុំ គ្រាន់តែខ្ញុំសម្គាសជាមួយអ្នកគ្រូឃើញខ្ញុំយំទេ។ ខ្ញុំមានការសោកស្តាយចំពោះជីប្អូន សោកស្តាយចំពោះជីវិតបងប្អូនក្រុមគ្រួសារសាច់សាលោហិតអីជាដើម។

ក៖ ហ្នឹងហើយ ពូអើយដោយសារបាត់បង់មនុស្សដែលខ្លួនឯងស្រឡាញ់ វាមិនងាយស្រួលប៉ុន្មានទេពូណោះ។

ខ៖ បាទ! ខ្ញុំមានប្រាថ្នាតែប៉ុណ្ណឹង អត់មានប្រាថ្នាអីក្រៅតែពីការសងសឹក។

ក៖ ហើយម៉េចទៅពូ ដល់ពេលទៅធ្វើអញ្ចឹងក៏ទៅធ្វើទ័ពតែម្តងទៅ?

ខ៖ បាទ!!ម៉ាបងថ្លៃញ៉ុមហ្នឹង បងខាងប្រពន្ធញ៉ុមហ្នឹងក៏ធ្វើទ័ពខ្ញុំក៏ទ័ពប្អូនខ្ញុំពីរនាក់ទៀតក៏ទ័ពគិតទៅគ្រួសារខ្ញុំធ្វើទ័ពច្រើន។

ក៖ ដោយសារនឹកឃើញអាដូចជាអាការសងសឹកអីចឹងទៅលោកពូណោះ?

ខ៖ បាទៗ! មានអារម្មណ៍មួយគិតឃើញតែពីការសងសឹកអត់មានចង់មានចង់បានអីទេ។

ក៖ ហើយមានបានសម្លាប់ពួកអាប៉ុលពតហ្នឹងបានខ្លះទេ?

ខ៖ បាន។

ក៖ បាទទៀត!

ខ៖ បាន!

ក៖ លោកពូធ្លាប់សម្លាប់។

ខ៖ បាញ់ចោលដោយផ្ទាល់ដៃម៉ង។

ក៖ ចាស! អត់មានសោកស្តាយវិញម៉ងហើយពូណេះ?

ខ៖ អត់មានសោកស្តាយ អត់មានគិតថាឈាមខ្មែរដូចគ្នានោះទេ។

ក៖ ដោយសារវាខូចពេកហ៎?

ខ៖ ពីព្រោះវាជាមនុស្សយ៉ង់ខ្នង កាប់សម្លាប់ខ្មែរគ្នាឯង អញ្ចឹងខ្ញុំបាញ់សម្លាប់ចោលនេះក៏ហាក់បីដូចជាឃាត់វាកុំឱ្យទៅសម្លាប់មនុស្សទៀតដែរ។

កៈ ហ៊ឺៗ! គ្មានអំពើបាបទេ ពូបើសិនជាយើងសម្លាប់មនុស្សបែបហ្នឹង។

ខៈ បាទ!

កៈ ដោយសារយើងមិនមែនអ្នកខុស។ ពួកវាបានវាបាបយើងអត់បាបទេ។

ខៈ បាទ! ឥឡូវឈប់ សូម្បីអ្នកគ្រូបង្រៀនខ្ញុំហ្នឹងក៏ដោយក៏សួរពីខ្ញុំថា ចុះសំអូនដែលខំរៀន តើខ្ញុំប្រាថ្នាចង់បានអី? ចង់ធ្វើអី? ខ្ញុំនិយាយប្រាប់អ្នកគ្រូខ្ញុំប្រាថ្នាគឺធំខ្លាំងបំផុតគឺការសងសឹកហ្នឹងតែម្តង។

កៈ គឺធ្វើទាហាន។

ខៈ ដល់អញ្ចឹងអ្នកគ្រូនាំទៅដល់នាយកនាំទៅសម្ភាសដូចអ្នកគ្រូអញ្ចឹង តែសរសេរដាក់ក្រដាស។

កៈ ហើយតែម៉េចយកទៅនាយក?

ខៈ យកទៅនាយកហ្នឹង គេយកទៅឱ្យសម្ភាសចុះហេតុអីក៏មានការឈឺចាប់ហេតុអីក៏ចេះតែចង់សងសឹកម្ល៉េះ។ ខ្ញុំថាបើខ្ញុំមិនចង់សងសឹកម៉េចប្អូនខ្ញុំក៏ស្លាប់។

កៈ ហ៊ឺៗ!

ខៈ សម័យអត់ឃ្លាន បងប្អូនជីដូនជីទួតជីលួតជីលា ខ្ញុំស្លាប់ក្រោយដៃអង្គការខ្មែរក្រហមមិនមែនចំនួនតិចអ្នកទេ។ អញ្ចឹងខ្ញុំមានប្រាថ្នាតែមួយគឺការសងសឹងហ្នឹងតែម្តង។

កៈ ចាស!

ខៈ ខ្ញុំធ្វើចម្បាំងគឺនិយាយរួមគឺបញ្ហាមិត្តគឺស្លាប់នៅក្នុងដៃខ្ញុំច្រើន។

កៈ បើគិតត្រួសៗទៅប៉ុន្មានគ្រឿងហើយដែលពូបាញ់?

ខៈ ហ៉េ! បើគិតមួយត្រួសៗមិនទាបជាង៥០នាក់ទេ។

កៈ តែពូសុទ្ធតែពួកប៉ុលពតទាំងអស់?

ខៈ បាទ!

កៈ ចាស! នៅក្នុងព្រៃនៅប៉ៃលិនហ្នឹងពូហេហ៉េ?

ខ៖ បាទ! វាយតាំងពីសំឡូត វាយតាំងពីយើង វាយតាំងពីផ្លូវច្រកចង្អៀត វាយរហូតដល់អូររាំង ខ្វារ វាយរហូតដល់ដីក្រហមដល់វត្តចាស់វាយរហូត ហើយវាយសម្រេចហើយ ហើយបានបង មកវាយនៅខាងឪវ៉ាល់ បរសេដ្ឋ កាត់ផ្លូកនេះទៀត។

ក៖ ហ្អ៎! អញ្ចឹងច្រើនកន្លែងណាស់ពូហី?

ខ៖ បាទ! វាយកន្លែងហ្នឹងហើយពួកខ្មែរក្រហម វាព័ទ្ធកងទ័ពខេត្តយើងពពកវិលកោះធំ យើង នេះ ពួកខ្ញុំទៅមានរួចឯណាទាល់តែជិះយន្តហោះទៅ។

ក៖ ហ៊ឺៗ!

ខ៖ ជិះកប៉ាល់ហោះទៅ ជិះអាឧត្តម្ពភេសជ្ជហ៎ា។

ក៖ ចាស!

ខ៖ ១៦គ្រឿងទព័ ទៅចុះបានតែកម្ពស់ហ្នឹងលោតដីមក។

ក៖ ហ៊ឺៗ!

ខ៖ ចុះវាបាញ់វាអត់ឱ្យចុះ វាយ៣យប់៣ថ្ងៃដាច់បាយដាច់ទឹកបានវាយបែក។ ចាប់ឈ្លើសឹក បាន២០០នាក់ អាហ្នឹងសល់ពីងាប់ហ៎ា សល់ពីងាប់ទៅជាង២០០នាក់ ដាក់បានអា៦ដំរីទឹក ដឹងយកមកដាក់កងសេនាធំប្រគល់ឱ្យវីរសេនាធំយើងចប់ការ។

ក៖ ពូចាំបានច្រើនណាស់បានល្អណាស់។ ចាស! ហើយពូ ពូដូចបានប្រាប់ថាពូរៀនអីគេបាន រៀនពេទ្យបានរៀនអីគេដែរពូហ៎េ?

ខ៖ បានរៀន រៀនពេទ្យហ្នឹងរៀនហ្នឹង គឺសម័យហ្នឹងវាលែងចង់ផុតសង្គ្រាមទៅហើយ។ បើនិ យាយរួមផុតទៅហើយហ្នឹង។

ក៖ ចាស! ហើយខ្ញុំរៀនបានសញ្ញាប័ត្របានសញ្ញាប័ត្របានរៀនពេទ្យហ្នឹង ប៉ុនខ្ញុំរៀនពេទ្យ ហ្នឹងពេទ្យអង្គការមិនមែនរៀនពេទ្យហ្នឹងពេទ្យរដ្ឋពេទ្យអីចឹងទេណា៎។ ខ្ញុំរៀនពេទ្យអង្គការកូន គេកើតមកវះអត់យកលុយទេ តែបើគេជូនសារគុណអើទទួលទៅ។

ក៖ ចាស!

ខ៖ សារគុណហ្នឹង ៣0,000-៥0,000 អីចុះបើបូសដូចយ៉ាងក្មេងប៉ុណ្ណឹងអីបូសប៉ុណ្ណឹងអីយ កទៅវះនៅពេទ្យរដ្ឋ៥0ដុល្លារអីណោះ ហើយដល់អញ្ចឹង គេចេះតែយកមកយើងអីចឹងទៅ។

កៈ ចាស!

ខៈ គេសួរយកប៉ុន្មាន? ខ្ញុំថាខ្ញុំអត់យកទេ ដល់អញ្ចឹងគេអាណិតគេជូនសារគុណ២០,០០០ ៣០,០០០អីទៅ។

កៈ ចាស! ពូហ្នឹងពេលហ្នឹងរៀនពេទ្យហ្នឹងរៀនមកពីណាវិញ?

ខៈ រៀនពីអាមេរិកកាំងមក។

កៈ ហ្អ៎! គេចុះមកជួយមកអីឬក៏យ៉ាងម៉េចពូ?

ខៈ ចុះមកបង្រៀនឱ្យយើងធ្វើពេទ្យអីចឹងម៉ង។

កៈ ហើយបានប៉ុន្មានខែធ្វើបានហ្នឹង។

ខៈ រៀន២ឆ្នាំ រៀន២ឆ្នាំខ្ញុំយកបានមីនីសាំង។

កៈ ហ៊ឺ! យូរដែរហ្នឹងពូ។

ខៈ បាទ! ដល់ពេល។

កៈ ហើយអញ្ចឹងមិនព្រមតយកតម្រិះវិជ្ជាទៅទៀតទៅអត់ទេពូ?

ខៈ ដល់ពេលខ្ញុំរៀនតទៅទៀត រៀនៗនៅ៣ខែទៀត ត្រូវប្រឡងយក សញ្ញាបប័ត្រវេជ្ជបណ្ឌិត ទទួលអត់បានប្រឡង។

កៈ ម៉េចអញ្ចឹងវិញពូ?

ខៈ ដូចជាខ្ញុំជម្រាបមុនហ្នឹងដូចកាលដែលសម្ភាសប្រពន្ធខ្ញុំអីចឹងណា៎ ខ្ញុំវាមានបញ្ហានៅក្នុង សហគមន៍។

កៈ ចាស!

ខៈ ដល់ហើយដើរចេញទៅមិនបាច់ប្រឡងអីទេ ប៉ុន្តែសញ្ញាប័ត្រនោះក៏ខ្ញុំមានរួចទៅហើយ។

កៈ ចុះមិនព្រមទៅរកកន្លែងណាផ្សេងទៀត ទៅពូមិនមែនមានតែកន្លែងមួយហ្នឹងទៀតណាពូ ហោ៎?

ខៈ ខ្ញុំទៅតើខាងអង្គការរ៉ាក់ខ្ញុំទៅអង្គការសេវេន ខ្ញុំទៅខាងអង្គការម៉ារីនុល។

កៈ លោកពូមិនព្រមនៅធ្វើទាល់តែឥឡូវ ម៉េចបានពូឈប់អាការងារទាំងអស់ហ្នឹងវិញ?

ខ៖ ខ្ញុំឈប់ពីព្រោះមកជួយប្រពន្ធ ជួយប្រពន្ធឈឺប្រកាច់ប្រកិនៗអីចឹងមកជួយប្រពន្ធទៅយក មកយកប្រពន្ធមកដាក់ពេទ្យជ័យជម្នះយើងនេះ។

ក៖ ហ៊ឹៗ!

ខ៖ នឹកឃើញពិតតែថាយើងចេះជំនាញមែន  ប៉ុន្តែយើងគ្មានឧបករណ៍គ្រប់គ្រាន់ដូចជាយ៉ាងអើបំពង់ខ្យល់អុកស៊ីសែន បំពង់ថត ឧបករណ៍ថត អត់មានឧបករណ៍ ដឹងតែពីថ្នាំហើយនិងសីរ៉ាំងចាក់ ហើយនិងសារ៉ូមអីហ្នឹងម៉ង។ បាទ! ប៉ុន្តែដល់ពេទ្យគ្រុបក្រណាត់សប្រពន្ធខ្ញុំហ្នឹងម្ដាយក្មេកខ្ញុំម្ដាយគាត់ហ្នឹងយំឹងទៅ ខ្ញុំថាមិនបាច់យកប្រពន្ធខ្ញុំទៅដាក់សាលខ្មោចទេ។ ខ្ញុំហៅកង់បីដាក់ប្រពន្ធខ្ញុំមកផ្ទះនៅចាក់អង្រៃក្រោមនោះ យកដាក់ហ្នឹងខ្ញុំទិញថ្នាំ សុទ្ធតែកំពូលៗថ្នាំយកទៅចាក់ឱ្យផ្ទាល់ដៃ សារ៉ូមដាក់ឱ្យផ្ទាល់ដៃ។

ក៖ ហ្នឹងហើយ។

ខ៖ ៣ថ្ងៃក្រោយប្រពន្ធខ្ញុំដឹងខ្លួនរកបបរ ខ្ញុំថាបានខ្ញុំហើយ។

ក៖ ចាស!

ខ៖ ហើយប្អូនស្រីប្អូនអីប្អូនពៅអីខ្ញុំហ្នឹងអញ្ចឹង កូនមានបញ្ហាអីដូចបូសដូចខ្មោរអីខ្ញុំរះឡើងពេញក្បាលទាំងអស់។

ក៖ ចាស!

ខ៖ ហើយរះតែម្ដងលែងកើតទៀតហើយព្រោះយើងចាក់ថ្នាំផ្ដាច់។

ក៖ អញ្ចឹងពូដល់ពេលការរៀបការវិញ ពូរៀបការជាមួយប្រពន្ធលោកពូគាត់ឈ្មោះអីគេដែរ?

ខ៖ គាត់ឈ្មោះទូចស្រី អានេះគាត់ដាក់ត្រកូលខាងឪពុក ត្រកូលម្ដាយគាត់ដាក់ម៉ែនស្រី។

ក៖ ពូរៀបការជាមួយមីងនៅឆ្នាំណាវិញ?

ខ៖ នៅ នៅឆ្នាំ១៩០០ប៉ុន្មានទេ កាលហ្នឹង។

ក៖ ពូនិយាយមិញ៨៣ (១៩៨៣) ហ៎?

ខ៖ ៨៤(១៩៨៤)ហ៎មិន៨៣ទេ(១៩៨៣)៨៤(១៩៨៤)។

ក៖ អញ្ចឹងប្រាប់មីងមិញ៨៣(១៩៨៣) ឥឡូវដូរហើយ៨៤(១៩៨៤)។

ខ៖ ទេ ដូចនឹកចាំដែរ។

កៈ អញ្ចឹងមិញមីងប្រាប់ហើយថាមិញ គឺស្រឡាញ់គ្នាដំបូង គឺឃើញគ្នាពេលទៅលក់ដូរនៅផ្សារពេលពូមីងអីទៅលក់នៅផ្សារពូហេ៎?

ខៈ និយាយជាមួយទៅប្រពន្ធខ្ញុំ ចិត្តមកនៅជាមួយខ្ញុំ ខ្ញុំអត់ដឹងខ្លួនផងហ្នឹង។

កៈ ចិត្តម៉េចពូ?

ខៈ ចិត្តមកនឹករកខ្ញុំហ្នឹងហា៎ ខ្ញុំអត់ដឹងខ្លួនមែន។

កៈ អត់ដឹងធ្លាក់ក្នុងអន្លង់ស្នេហ៍គេពេលណា។

ខៈ អត់ដឹងទេ ដល់រកផ្ទះខ្ញុំឃើញផ្ទះច្បារអំពៅហ្នឹង តែព្រលឹមឡើងទៅដល់ហើយ។

កៈ ប្រពន្ធហេ៎?

ខៈ បាទ!

កៈ ហេមីងហិ។

ខៈ ព្រលឹមឡើងទៅដល់ហើយ ដល់អញ្ចឹងម៉ែខ្ញុំបង្កើតខ្ញុំហ្នឹងមកហៅម៉ែក្មេកហ្នឹងហា៎យកទៅពីចាក់អង្រៃនេះទៅហិ ដល់ពេលម៉ែក្មេកមកឱ្យជម្រាបសួរឱ្យហៅគាត់ម៉ែក្មេកហៅអីប៉ុន មិនទាន់បានខុសឆ្គងអីទេ។ គាត់ថាមើលទៅកូន២នាក់ហ្នឹងបេះមិនចេញទេ ឥឡូវមើលជន្លងស្រីគិតម៉េច ម៉ែក្មេកខ្ញុំថាខ្ញុំមិនដឹងទេ គាត់ថាហា៎។

កៈ ចាស!

ខៈ ខ្ញុំមិនដឹងទេ ស៊ីសងលើជន្លងឯងទេធ្វើអីធ្វើទៅ ប៉ុន្តែកាលណោះរបរខ្ញុំហ្នឹង គឺរបរលីសែងខ្ញុំមិនទាន់បានអីទាំងអស់នៅលីសែង។ តាំងពីសម័យយើងនៅចាយលុយរៀលនោះណា៎។

កៈ ចាស!

ខៈ លីសែងអីចឹងទៅបាន៣០ បាន៥០ បាន៧០ បាន១០០អីចឹង ទៅយកទៅឱ្យម្ដាយបង្កើតនេះទុក ដល់ពេលរៀបចំហ្នឹងឱ្យមានលុយបណ្ដោយ នេះមិនបានជាការរហូតដល់ថ្នាក់គុកៅអីនេះអីទេ តែគ្រាន់តែថាសែនធំដែរ គ្រាន់តែសម្លភ្ញៀវ៥០ ៦០នាក់ហូបអត់អស់ផង ម្ហូបហា៎។

កៈ ចាស!

ខ៖ ហូបអត់អស់ទេ ហើយអញ្ចឹងក៏លើកដៃលាដៃសំពះលាម្ដាយបង្កើតមកនៅជាមួយប្រពន្ធ នៅជាមួយប្រពន្ធនៅជាមួយម៉ែក្មេក និងជីវភាពរបស់ខ្ញុំពិបាកណាស់ ហើយបងៗពង្រាត់ពង្រាស់អត់ឱ្យយកទេ។

ក៖ ម៉េចអញ្ចឹង?

ខ៖ ទៅយកអីស្រីកាច់កំប្លោក ហើយគេខឹងដល់ម៉ែខ្ញុំទៀតថា អាហ្នឹងបងថ្លៃខ្ញុំហ្នឹងស្រី ម៉ែឯងនិយាយបងខ្ញុំឱ្យទុកកូនឱ្យវា។ ឥឡូវម៉ែឯងទៅដូរពាក្យខ្លួនឯងធ្វើអីខ្ញុំថា ជំនាន់ហ្នឹងភ្ជាប់ពាក្យភ្ជាប់សម្ដីថាឱ្យយកកូនគាត់ម៉េចក៏មិនឱ្យពួកខ្ញុំដឹងមុន។ បើដឹងទៅធ្វើម៉េច បើយើងជំពាក់ងណោះទៅ ហើយចុះបើអត់ដឹងផងឱ្យខ្ញុំធ្វើម៉េច។

ក៖ ចាស!

ខ៖ ឥឡូវអង្ករក្លាយជាបាយធ្វើម៉េច អាហ្នឹងមកពីរឿងចាស់ៗនិយាយគ្នាអត់ឱ្យកូនៗដឹងដល់ឥឡូវកូនៗអត់ដឹង អង្ករទៅជាបាយបាននិយាយ វាហួសពេលទៅហើយ។

ក៖ ចាស! អញ្ចឹងមានតែទៅមុខហើយ។

ខ៖ បាទ!

ក៖ ហើយពូពេលហ្នឹងអោយថ្លៃជំនូនថ្លៃអីដែរតើហ៎ទៅខាងមីងពូហ៎?

ខ៖ បាទ! អានេះអញ្ចេកទេ អានេះជំនូនហ្នឹងវាបិតនៅលើលុយកាក់ខ្ញុំទេ គឺទិញមួយគ្រឿងមួយគ្រូវកុំឱ្យគេពិបាកអស់លុយអស់កាក់តែប៉ុណ្ណឹង។

ក៖ ដោយសារពេលមុនក៏មានអីណាស់ណាមិនមានអីណាស់ណាដែរពូណោះ?

ខ៖ មិនមានអីទេគ្នាកាច់កំប្លោកទេ។

ក៖ ចាស!

ខ៖ ហើយខ្ញុំលីសែង ពេលធ្វើនំបញ្ចុកឱ្យម្ដាយហើយព្រលឹមឡើង រែកនំបញ្ចុកឱ្យម្ដាយទៅលក់លីសែងនៅផ្សារហ្នឹង លីសែងនៅផ្សារច្បារអំពៅយើងហ្នឹង។

ក៖ ចាស!

ខ៖ ជួនកាលខ្ញុំរកទុកមកបានឡើង១០០ហើយនៅមានលុយចាយទៀត។

ក៖ ហ៊ឺៗ!

ខ៖ ខ្លះទៅដូចថាតាមពេលវេលាដែរណាំទៅអ្នកគ្រូ ឃើញថាមួយថ្ងៃរកបាន៣០អីចឹងទៅទុកឱ្យម៉ែយក ទៅទុកហ្នឹង២០ទៅចាយ១០ទៅ។

ក៖ ចាស! អញ្ចឹងពូពេលការជាមួយមីងកូនទាំងអស់ប៉ុន្មាននាក់មិញ?

ខ៖ កូនទាំងអស់១០នាក់។

ក៖ តែស្លាប់អស់ម្នាក់?

ខ៖ បាទ! ស្លាប់អស់ម្នាក់ទៅ។

ក៖ ពូប្រាប់ឈ្មោះឱ្យបានគ្រប់ទាំងអស់គ្នាមើលឈ្មោះអីគេខ្លះទាំងស្លាប់ទាំងរស់ហ្នឹងហាំ? បងគេដល់ពៅគេហាំ?

ខ៖ អញ្ចឹង!

ក៖ ចាស!

ខ៖ មួយឈ្មោះព្រំ វណ្ណី បងស្រីបង្អស់ មួយវណ្ណនេតហ្នឹងជាកូនទី២ប្រុស ទី៣កូន អាហ្នឹងយើងមិនបាច់និយាយកូនស្លាប់ទេហី?

ក៖ និយាយមកនិយាយមកអត់អីទេ។

ខ៖ អញ្ចឹង អញ្ចឹងទី១ព្រំ វណ្ណី ទី២ព្រំ វណ្ណនឿន ហៅស្រីខួច ។

ក៖ ស្លាប់ហ្នឹង?

ខ៖ បាទ! កូនហ្នឹងកើតមកស្អាតណាស់ ទី៣ព្រំ វណ្ណនេត ទី៤ព្រំ វណ្ណា ទី៥ព្រំ ដារា នោះអានោះមាឌប៉ុនពាងនោះ។

ក៖ ចាស!

ខ៖ ព្រំ ដារ៉ា មក ព្រំ ដារី មក ព្រំ ថាវី ព្រំ ថាវិន មកក្រោយព្រំ ពុតនេះ ក្រោយនេះកូនទាំងអស់១០នាក់។

ក៖ ចាស!

ខ៖ តែដល់ស្លាប់អាកូនទី២ហ្នឹងទៅវានៅតែ៩។

ក៖ ចាស! អញ្ចឹងពូទាំងអស់គ្នាសុទ្ធតែបានទៅរៀនទាំងអស់ហើយណោះពូណោះ?

ខ៖ បានទាំងអស់។

កៈ គ្រាន់តែថាតិចច្រើន។

ខៈ បាទ! មិនដឹងធ្វើម៉េចទេ តិចច្រើនអីអោយតែបានរៀន។

កៈ ដោយសារជីវភាពអីចឹងទៅពូហោ៎?

ខៈ បាទ! ហើយឥឡូវញ៉ុមមក អាការៈ ៣ អាការៈជម្ងឺរបស់ខ្ញុំណា៎៣។

កៈ ចាស!

ខៈ បេះដូងមួយ ពោះវៀនហើយនិងក្រពះ។

កៈ ហើយវាម៉េចពូបានវាដល់ថ្នាក់ឈឺបេះដូងហើយពោះវៀនក្រពះអីចឹង?

ខៈ បេះដូងហ្នឹង កាលពីខ្ញុំធ្វើចម្បាំងហ្នឹងវាខ្លាំ។

កៈ ហ្អ៎!

ខៈ ខ្លាំនឹងគ្រាប់។

កៈ ពូត្រូវគ្រាប់ដែរហ្នឹងអីចឹង?

ខៈ អត់ត្រូវទេ ។

កៈ លាន់?

ខៈ បាទ! តាំងពីខ្ញុំធ្វើទ័ពមកទល់នឹងនេះវាជម្ងឺបេះដូងហ្នឹង វាទៅឱ្យពេទ្យគេថតពេទ្យបច្ចុប្បន្នហ្នឹង ពេទ្យអង្គការគេថតគេយកទៅទេណា៎។

កៈ ចាស!

ខៈ ខាងយេស៊ូវ កាតូលិក គ្រាន់តែខ្ញុំហ្នឹងគេអស់ជាង១០០០ដុល្លារលើខ្ញុំហើយ ។

កៈ តែជាណោះពូណោះ?

ខៈ មិនជាទេ បើយើងចង់ជាទាល់តែយើងទៅអាមេរិក ទៅវះនៅហ្នឹង ជូនមួយនាទីវត់ដល់ ១៨០។

កៈ វាម៉េចដែរពូ វាបេះដូងរីកបេះដូចអី?

ខៈ បេះដូងហ្នឹងរីករីកហើយវាក្រាស់ទៅទៀត ដល់អញ្ចឹង។

កៈ ដល់អញ្ចឹង វាត្រូវការថ្នាំជាប្រចាំពូហោ៎?

ខៈ បាទ! ហើយថ្នាំនេះ។

ក៖ អញ្ចឹងពូអញ្ចឹងជាប្រចាំហូបថ្នាំហ្នឹងម៉ង?

ខ៖ បាទ!

ក៖ ហើយថ្នាំហ្នឹងទិញនៅហ្វាម៉ាស៊ី(ឱសថស្ថាន)ទិញនៅអីចឹងទៅពូហី?

ខ៖ បាទទិញនៅហ្វាម៉ាស៊ី (ឱសថស្ថាន)។

ក៖ ចាស! អញ្ចឹងមួយថ្ងៃៗអ្នកណាគេជាអ្នកផ្គត់ផ្គង់ថ្នាំអីទៅពូ?

ខ៖ ពីមុនជួនក៏កាតូលិកអីចឹងទៅ ជួនក៏ខ្លួនឯងអីចឹងទៅអ្នកគ្រូអើយ ជួនកាលគេចុះមកមិនទាន់យើងត្រូវទិញលេបដោយខ្លួនឯង។

ក៖ មានអង្គការមានអីមកជួយដែរពូណេះ?

ខ៖ មានខ្ញុំបើកុំមានអង្គការជួយខ្ញុំងាប់យូរណាស់ហើយ ។

ក៖ អញ្ចឹងល្អហើយពូគ្រាន់មានសង្ឃឹមខ្លះ។

ខ៖ បាទ! ហើយនេះថ្នាំនេះ លេបសម្រាប់ឱ្យបត់ជើងតូច។

ក៖ ចាស! បើមិនលេបស្វះពូហ៎?

ខ៖ វាអញ្ចេះបើកាលណាវាមិនលេបទេវាមិននោម ដល់វាអត់បត់ជើងតូចវាតឹង តែពោះវាបុកបេះដូងញ័រយកបណ្ដោយវាអញ្ចេក។

ក៖ ប៉ុន្មានឆ្នាំហើយពូឈឺជំងឺហ្នឹង?

ខ៖យូរហើយញ៉ុមហ្វ៎ គិតទៅមិនដឹងជាប៉ុន្មានឆ្នាំទេ!!ហើយនេះថ្នាំនេះឈ្មោះវាម៉ាឡូកាឌីលគឺបេះដូង អ្នកមិនដែលសោះគឺក្នុងមួយកាច់ជា៤ នេះគេដាក់សញ្ញាខ្វែងមកហិ។

ក៖ ចាសៗ! គេស្មាមឱ្យយើងកាត់ឱ្យហើយ។

ខ៖ ដល់ឥឡូវខ្ញុំអាចហើយ លេបបានម្ដងមួយគ្រាប់។

ក៖ ចាស!

ខ៖ តែពេលក្រពះពោះវៀនវាធ្វើទុក្ខ ទោះណាលេបថ្នាំហ្នឹង៣គ្រាប់ក៏វាអត់មានទៅណាដែរ វានៅតែអញ្ចឹង វាទៅមិនស្រួលអាក្រពះពោះវៀននោះ។ នេះសរសៃឡើងប៉ុនមេដៃនៅបណ្ដោយអីចឹងហិអ្នកគ្រូ។

កៈ ចាស! អញ្ចឹងលោកពូអាចនិយាយពីជីវិតរបស់លោកពូនៅក្នុងសម័យ សម័យសង្គ្រាមមក មើលពីលន់នល់មកមុន តើពូជួបរឿងអីគេខ្លះនៅក្នុងលន់នល់ហ៎ា មិនទាន់ប៉ុលពតទេ តើពូជួបរឿងអីគេខ្លះដែរ?

ខៈ ជួបកាលពីសម័យលន់នល់ហ្នឹង កាលសម័យលន់នល់ហ្នឹង មានសង្គ្រាមមួយ មានសង្គ្រាមមួយកាលលន់នល់នៅជំនាន់ហ្នឹង ធ្វើរដ្ឋប្រហារទម្លាក់សម្តេចឪ។ បាទ! រដ្ឋប្រហាររហូតដល់សម្តេចឪបង្កើត បង្កើតទ័ពមួយគេហៅថាទ័ពរំដោះ។ បាទ! វាយគ្នារគៃសទឹករគៃសដី ប៉ុន្តែឪពុកម្តាយខ្ញុំប្រយត្ន័ណាស់ ឪពុកម្តាយដ៏ល្អរបស់ខ្ញុំព្រួតដៃគ្នាជីកត្រង់សេឱ្យកូនជ្រកដល់ពេលទីបំផុតបានសង្គ្រាមអាដេញខ្មែរក្រហម និង លន់នល់ជាក្រោយ ។

កៈ ហើយក៏ពេល ពេលហ្នឹងពូមានអ្នកណាត្រូវគ្រាប់ត្រូវអីទេពូ ពេលជំនាន់លន់នល់?

ខៈ អត់ទេ គ្រួសារខ្ញុំរួច។

កៈតែអ្នកផ្សេងអីចឹងហ៎ាពូ?

ខៈ អ្នកផ្សេងត្រូវនៅផ្សារអ្នកលឿងយើងនេះ។

កៈ ហ្អ៎! អញ្ចឹងពេលនៅជំនាន់លន់នល់ពូនៅអ្នកលឿងទេអញ្ចឹងហ៎េ?

ខៈ បាទ! ពេលនៅអ្នកលឿងហ្នឹងចិន ចិនលក់បបរលក់បបរឈាមជ្រូក ដល់ពេលលក់បបរអីចឹងអួសទើបតែដល់មាត់ផ្សារ ស្រាប់តែគ្រាប់ហ្នឹងវាផ្ទុះមក អាគ្រាប់ផ្លោងយើងអា។

កៈ អាប៉ុមប៊ីអីហ្នឹងពូហ៎េ?

ខៈ មិនមែនអាប៉ុមប៊ីហ្នឹងទេ អាហ្នឹងរោយពីលើទេ។

កៈ ហ្អ៎!

ខៈ ដេញអាកាំភ្លើងអា១០៥វាផ្លោងមកវាធ្លាក់ ដល់ធ្លាក់ទៅផ្ទុះកាប់ដាច់កករហ្នឹង ដាច់កករហ្នឹងអាឈាមមនុស្ស ហើយនិង អាឈាមបបរវាក្រឡុកចូលគ្នាអស់។

កៈ ហើយអញ្ចឹងពូរួចផុតពីជំនាន់ប៉ុលពតមក វាម៉េចដែរបានជាលន់នល់វាយចាញ់ប៉ុលពតពូដឹងអត់?

ខ៖ ខ្ញុំគ្រាន់តែឮគ្រាន់តែឮចាស់ៗគាត់និយាយតៗគ្នា គាត់ថាសង្គ្រាមសម័យនោះសង្គ្រាមលាយឡំនឹងនយោបាយ។ បាទ! ដើម្បីអំណាចដើម្បីអញបានធ្វើធំនោះណាំ ធ្វើជានាយករដ្ឋមន្ត្រីធ្វើជាអីចឹងទៅ។

ក៖ ចាស!

ខ៖ ហើយបើលន់នល់ក្បត់សម្តេចឪ ស្រាប់តែឡើងទៅអង្គុយលើបង្គ័លរបស់ព្រះអង្គហាំ ហើយស្រែកមកអាពួកដែលនៅខាងក្រោមនេះថាអស់លោក រួចខ្ញុំអង្គុយនៅក្នុងរាជបង្គ័លនេះតាមរាជបំណងរបស់អស់លោក តើសាកសមទេ? ចុះអាក្រោមម៉េចហ៊ានថាមិនសាកសមមើលមើល ដល់អញ្ចឹងបរមីបង្គ័លវាយស្លាប់មួយចំហៀងខ្លួន។

ក៖ នៅលើហ្នឹងម៉ងហោ៎?

ខ៖ បាទ! ខ្មែរក្រហមត្រូវផ្តួលលន់នល់ហ្អ៎។ អាហ្នឹងធ្វើរដ្ឋប្រហារម្តងម្នាក់ កាលពេល សម័យលន់នល់ធ្វើរដ្ឋប្រហារទម្លាក់សម្តេចដល់មកខ្មែរក្រហមនេះវាយលន់នល់វាយលន់នល់។

ក៖ ចាស!

ខ៖ ដល់អញ្ចឹងលន់នល់ហ្នឹងដឹកដៃប្រពន្ធ អាយុ១៦ឡើងកប៉ាល់ហោះទៅនៅអាមេរិកហើយ។

ក៖ ហ្អ៎!

ខ៖ ហើយកាលហ្នឹង លន់នល់ហ្នឹង ក៏ទៅជួលអាមេរិកឱ្យមកពោយគ្រាប់នៅក្នុងស្រុកខ្មែរហ្នឹង។

ក៖ ទម្លាក់ហ្នឹងតែក្នុងនាមដើម្បីសម្លាប់ពួកប៉ុលពតទេព្វណោះ?

ខ៖ មកសម្លាប់តែពួកប៉ុលពត ប៉ុន្តែ...

ក៖ វាត្រូវប៉ះពាល់ប្រជាជន។

ខ៖ ដល់ពេលងាប់មានទៅងាប់ប៉ុលពតណាអី ងាប់ប្រជាជននេះ វាអាងថាមិនមែនជីវិតរបស់វា វាទម្លាក់ពោយយកទៅ ហ្អែងងាប់អាណាងាប់ទៅ អាណាងាប់ម៉េចងាប់ទៅ សូម្បីតែគោក្របីក៏អត់លើកលែងបានដែរ ត្រូវស្លាប់ហើយកាលពីសម័យលន់នល់ហ្នឹង ចិញ្ចឹមកងទ័ពលន់នល់ផ្ទាល់ហ្នឹងណាំ តាមរយៈការទម្លាក់ឆ័ត្រស្បៀងអាហារ គឺទម្លាក់ទាំងអស់ អាដាកាតាវាដឹកមកទម្លាក់ឆ័ត្រនេះ។

ក៖ ចាស! អញ្ចឹងក្នុងសង្គ្រាមបីបួនជំនាន់នេះ ខ្ញុំសូមនិយាយថាវាល្មមគ្រប់គ្រាន់ហើយ។

កៈ សង្ឃឹមថាវានឹងមិនមានទៀតហាំ។

ខៈ ហ្នឹងហើយសង្ឃឹមថានឹងមានម្តងទៀត ពីព្រោះដែលពេលមានបំណងថាចង់សងសឹក ខ្ញុំក៏សងសឹងរួចហើយអស់ដែរ។

កៈ ឈាមត្រូវសងដោយឈាមហើយហើយពូហ៎?

ខៈ បាទ! សងរួចអស់ហើយវាសមល្មមថាវាត្រជាក់ទៅហើយ កាលពីសម័យនោះខ្ញុំបញ្ជាការគរថ្នាក់អនុសេនីយ៍ទោល ស្គាល់អនុសេនីយ៍ទោជាស្អីទេ?

កៈ ហ្នឹងហើយខាងទាហានអីហ្នឹងមានងារមានសក្តិមានអីឱ្យអីចឹងទៅពូណោះ?

ខៈ បាទ!

កៈ ចាស!

ខៈ អនុសេនីយ៍ទោលហ្នឹងសក្តិ២ ខ្ញុំទទួលបន្ទុកបក្សជន ដល់វាឆ្អែតនឹងសង្គ្រាមហើយក៏ វាសមល្មមក៏វាអស់សង្គ្រាមហើយ ខ្ញុំបានប្រគល់ឯកសារ ប្រគល់អាកាំភ្លើងប្រគល់ខោអាវជូនទៅខាងរដ្ឋាភិបាលវិញ ខ្ញុំសុំឈប់។

កៈ ពូបើនៅធ្វើទល់ឥឡូវមិនមែនតូចទេនេះ។

ខៈ ទោះតែធ្វើដល់ឥឡូវក៏ធ្វើមិនកើតដែរ ព្រោះបេះដូងវាអញ្ចឹងទៅហើយ។

កៈ តែពេលនេះបើសិនជាម៉េចៗក៏ធ្វើការនៅបម្រើការងាររដ្ឋ តែនេះឈឺអីគេមើលគេអីគេព្យាបាលឱ្យជាហើយពូណាំ។

ខៈ បាទ! កាលហ្នឹងវាប្រថុយប្រថានដែរ ព្រោះបន់ឱ្យតែវានេះទៅនឹងអាលហ្នឹងមករកប្រពន្ធរកកូន ពីព្រោះចេញទៅច្បាំងម្តងៗជូនកាលដេកបង្ហូរទឹកភ្នែកនឹកប្រពន្ធ ប៉ុន្តែធ្វើម៉េច បើតម្រូវយើងត្រូវសងសឹកទៅហើយវាអញ្ចឹង ប្រពន្ធខ្ញុំនេះ២-៣ខែ មិនទាន់ហ៊ានសិតសក់ក្បាលទេ កន្ទេលអត់ដែលហ៊ានបោសទេ ស្រូវអត់ដែលហ៊ានហាលទេ បោកគក់ខោអាវក៏អត់ដែលហ៊ានបោកគក់ដែរ ហើយអ្នកដែលមិនធ្វើតាមប្រពន្ធខ្ញុំហាំ ស្លាប់សឹងគ្រប់គ្នា។

កៈ ម៉េចអញ្ចឹងវិញពូ?

ខៈ មិនដឹងជាខុសយ៉ាងម៉េច ពេលគេបាញ់មកត្រូវគ្រាប់ងាប់ហ្នឹង បើមិនស្លាប់ក៏ត្រូវកំបុតដៃកំបុតជើងដែរ។

កៈ វាម៉េចវិញទៅពូខ្ញុំអត់យល់?

ខៈ អាកំបុតដៃកំបុតជើងហ្នឹងដើរទៅជាន់មីន។

កៈ និយាយថាមីងនិយាយម៉េចបានអីចឹង? វាម៉េចបានអីចឹង?

ខៈ ពីព្រោះនេះជាជំនមរបស់ខ្ញុំតាំងពីបុរាណកាលមក។

កៈ ចាស!

ខៈ អត់ហ៊ានសិតសក់ អត់ហ៊ានបោសកន្ទេល អត់ហ៊ានបោកកន្ទេល អត់ហ៊ាន។

កៈ អញ្ចឹងមីងអ់តហ៊ានធ្វើទេអីចឹង?

ខៈ អត់ឱ្យធ្វើទាំងអស់ ហើយគ្នាគោរពតាមបានទាំងអស់។

កៈ ហ៊ឺៗ! ហើយម៉េចទៅអីចឹងវិញពូ ហើយម៉េចទៅបានបានមួយហ្នឹងវិញវាថីទៅ?

ខៈ ពីព្រោះការដែលធ្វើសង្គ្រាមដូចជាចាស់បុរាណគាត់បានពោល។

កៈ ហ៊្អ! អញ្ចឹងដោយសារចង់ការពារពូអីអីចឹងៗអីបានត្រូវតែគោរពអីចឹងទៅណោះ?

ខៈ បាទ! ពីព្រោះកាលដែលធ្វើសង្គ្រាមមិនខុសពីមោរទៅទាក់ដំរីទេ បើប្រពន្ធគិតតែពីសង្ហា ដំរីបោកប្តីស្លាប់ឃើញទេ។ អញ្ចឹងពីដើមឡើយរបស់ខ្មែរយើងតាំងពីបុរាណ មិនមែនតែខ្ញុំតែម្នាក់ទេ ជាទូទៅខ្មែរទាំងអស់ ត្រូវចេះតមផ្លូវហ្នឹង ពីព្រោះប្តីទៅធ្វើចម្បាំងមិនខុសពីមោរទៅទាក់ដំរីដូចមិញហ្នឹងអីចឹងហ៎។ បើសិនជាប្រពន្ធសិតសក់ ប្រពន្ធដើរ ស្មាទោស ប្រពន្ធដើរដល់ទៅទាក់ប្រុសបប្តីស្លាប់ហើយ កុំសង្ឃឹមមានជីវិតមកវិញ។

កៈ ហ៊្អជំនម។

ខៈ បាទ!

កៈ ចាស!

ខៈ បើមិនត្រូវគ្រាប់ស្លាប់ក៏ត្រូវពស់ចឹកស្លាប់ដែរ។

កៈ ហ៊ឺៗ!

ខៈ ឬក៏ខ្លាត្រូវហែកយកទៅស៊ីដែរ។

កៈ អញ្ចឹងពូសម្រាប់នេះវិញ សម្រាប់ជំនាន់ប៉ុលពត ពូអត់ទាន់និយាយប៉ុលពតទេ បានតែលន់នល់អីធ្វើធ្វើទាហាននិយាយហើយហើយ តែប៉ុល ពតថ្ងៃដំបូងវាម៉េចដែរពូ? ចូលដល់រហូតមក?

ខៈ ថ្ងៃដំបូងពីសម័យណា សម័យខ្មែរក្រហមណេះ?

កៈ ចាស!

ខៈ កាលពីសម័យប៉ុលពតហ្នឹងផ្លាស់ប្តូរនយោបាយលឿនណាស់ មកពួកសោរធឹម មកពួកប៉ាៗជីវីអីចូលមកផ្លាស់ប្តូរសង្គមចាប់ពួកអាអង្គការ អង្គការពីនេះចងយកទៅសម្លាប់ អ្នកណាមិនសម្លាប់ក៏ទម្លាក់បុណ្យស័ក្តចោលដែរ ឱ្យនៅជាប្រជាជនធម្មតា ហើយគេឡើងកាន់ដំណែងហើយគេចាប់ផ្តើមកាប់សម្លាប់មនុស្ស។

កៈ គ្រប់ដណ្តប់បានពូណោះ?

ខៈ បាទ! កាលពីសម័យខ្មែរក្រហមហ្នឹងមានទាន់សម្លាប់ឯណា ដល់មកផ្លាស់ប្តូរសោរធឹមផ្លាស់ប្តូរអីវាចាប់ផ្តើមបង្កើតថាអ្នកប្រាជ្ញធ្លាក់រណ្តៅ អ្នកឃ្លៅឡើងឋានសួគ៌។ បាទ! យល់ពាក្យហ្នឹងទេ?

កៈ ចាស! យល់។

ខៈ ពីព្រោះហេតុអីបានថាអ្នកប្រាជ្ញធ្លាក់រណ្តៅឱ្យតែអ្នកចេះដឹងឃើញទេ និស្សិត បញ្ញាវន្តឱ្យតែចេះៗយកទៅសម្លាប់ចោលទាំងអស់។ សូម្បីថាតែអ្នកចម្រៀងយកទៅសម្លាប់ទាំងអស់ហើយវាទុកឱ្យអាមាន់តែវង្វើយមើលថ្ងៃកាន់ជាអង្គការវិញ

កៈ ទៅនយោបាយឆ្កួតលប់អីនោះវិញពូ?

ខៈ បាទ! ដល់អញ្ចឹងវាបង្វក់អ្នកដែលអវិជ្ជាឱ្យធ្វើធំដើម្បីឱ្យ...

កៈ ដល់អញ្ចឹងវាឆាប់ជឿពូណោះ?

ខៈ បាទ! ដើម្បីឱ្យវាកាប់វាសម្លាប់ ហើយមនុស្សតែអវិជ្ជាស្អីក៏វាធ្វើដែរ។ បាទ! ហើយដើរអញ្ចឹងពាក់នាឡិកា ហើយនាឡិកាយកមកពាក់នឹងដៃសុទ្ធតែសម្លាប់គេហើយយក។

កៈ ហ៊ឺៗ!

ខ៖ យកមកពាក់ សួរថាមិត្តបងម៉ោងប៉ុន្មានហើយ? ងើយមើលថ្ងៃហើយហ៊ីម៉ោង១ ប៉ុន្តែថាយើងដឹងហើយ វាសុទ្ធអីចឹង។

ក៖ អ្នកលួង់វាអីចឹងណោះពូណោះ។

ខ៖ បាទ! ហើយបើវាប្រជុំម្តងៗ គឺដើម្បីគឺថាគឺថាដើម្បីធ្វើស្រែឱ្យបាន៣ហិចតាហ៎ា ៣តោនទៅ ៧តោនគឺដើម្បីខ្ញុំថាស្អីក៏ដើម្បីវាក៏ច្រើនម្ល៉េះវាយ។

ក៖ វាអញ្ចឹងមែនហ៉េពូហ៉េ?

ខ៖ បាទ! ហើយសំបុត្រអីយកមកអាន អានហ្នឹងមិនអានឱ្យឮទេព្រោះវាអត់ចេះ ហ៊ីមិនអីទេ អង្គការទទួលស្គាល់ហើយ  ហើយអង្គការមិនដឹងអាណាអង្គការ លើមិនដឹងអាណាអង្គការក្រោមទេ មិនដឹងទេ ។

ក៖ ពូដែលឮប៉ុលពតអីហ្នឹងទេ ពូថានៅណានៅណីអីហ៎ា ឮតែជំនាន់អីចឹងហ្អ៎ តែមានឮថាពួកគេអាមេធំហ្នឹងនៅឯណាអត់?

ខ៖ មេធំប៉ុលពតហ្នឹងឯង។

ក៖ ដឹងហើយ ប៉ុន្តែពួកវាមានទីតាំងនៅអីណាអីណាមានគេប្រាប់អីទេ?

ខ៖ នៅតើទីតាំងបង្កើតនៅបរប៉ៃលិន។

ក៖ ហ្អ៎!

ខ៖ ជាទឹកដីរបស់ពួកវាតែម្តង ជាទឹកដីរបស់ពួកវាហើយមើល ពួកវាផ្តាច់ខ្លួន វាបំបែកក្រុមហ៎ា។ គេហៅបំបែកក្រុមនៅគ្រប់បណ្តាខេត្តទាំងអស់ដែលមានភ្នំ វានៅតែអីចឹងៗទេ។

ក៖ ពូពេលហ្នឹងដឹងថាអ្នកណាគេមេធំជាងគេនៅហ្នឹងខ្លះទេ?

ខ៖ ដឹង ប៉ុលពត ហ្នឹងជាអគ្គមគ្គុទេសន៍ដ៏ឆ្នើមក្នុងសម័យនោះគឺមានតែឈ្មោះប៉ុលពត ហ្នឹងហើយដែលធំជាងគេ។

ក៖ ចុះអាក្រោមៗមកទៀតអាហ្នឹងគេអត់អីអត់មានឮអីគេណាពូហ៉េ?

ខ៖ ក្រោមៗអត់មានទេ អត់មានទេ ក្រោមៗមកមានខៀវសំផន សឺន សាន។

(ភរិយា)៖ ខៀវ សំផនហ្នឹងមេគេហើយ។

ក៖ តែមិនដែលឃើញមុខទេពូហ៉េ?

ខ៖ ឃើញ ។

ក៖ ឃើញមុខទៀត?

ខ៖ បាទ! ឃើញ។

ក៖ វាចុះមកដល់មូលដ្ឋានហ្នឹងឬក៏ម៉េចពូមកធ្វើអីគេវិញ?

ខ៖ វាចុះមកវាកោះប្រជុំវាដូចថាថ្ងៃនេះ ត្រូវចង់ឱ្យស្តាប់សម្តីប៉ុលពត ដែលជាអគ្គមគ្គុទេសន៍ដ៏ឆ្នើមហ្នឹង ត្រូវឱ្យឈប់ការងារមួយថ្ងៃ ។

(ភរិយា)៖ មួយថ្ងៃហ្នឹងឱ្យយើងស្លៀកពាក់ឱ្យស្អាត។

ខ៖ ហើយខោអាវវាសម្រាប់ស្អាតបំផុតគឺខោខ្មៅអាវខ្មៅ។ បាទ!

ក៖ ស្មើគ្នាទាំងអស់។

ខ៖ ស្មើទាំងអស់។

ក៖ ហើយដល់ពេល ដល់ពេលមកទទួលអីចឹងមានទទួលអីហូបអីអត់ពូ?

(ភរិយា)៖ បានហូបឆ្ងាញ់តែមួយពេលហ្នឹង។

ខ៖ វាបញ្ជាឱ្យដែរ ឱ្យចុងភៅហ្នឹង កាប់គោកាប់ក្របីអីមួយពេលអញ្ចឹងទៅ មួយពេញមួយថ្ងៃហ្នឹង។

ក៖ ខ្ញុំឆ្ងល់ណាស់ពូ ពួកលើៗវាដឹងថាខាងក្រោមហ្នឹង វាអត់មានអីស៊ីអីអត់? តាមពិតសុទ្ធតែដឹងតើហ៎?

ខ៖ ដឹងសុទ្ធដឹងប៉ុន្តែ វាអញ្ចេះដែលធ្វើស្រែកកើតណា៎ ពីព្រោះទូទាំងប្រទេស មិនមែនធ្វើតែមួយខេត្តណាមួយទេ។

ក៖ គ្រប់កន្លែង!

ខ៖ បាទ! គ្រប់កន្លែងទាំងអស់។ វាយកស្រូវហ្នឹងទៅដូរសម្ភារៈច្បាំង ដល់អីចឹងបបរមានតែជូនកាលវាយកកូនការយកទៅដូសបបរកូនការហ្នឹង។

ក៖ ហ្អ៎! អញ្ចឹងខ្ញុំយល់ហើយ ពេលពូនិយាយមកខ្ញុំយល់បណ្តោយ ពេលមុនខ្ញុំអត់ដឹងទេពូណា៎ ដោយសារពូនិយាយថាដូរសម្ភារៈច្បាំងហ្នឹងមានន័យថាដោយសារ...

ខ៖ ព្រោះប្រទេសហ្នឹងពីដើមអត់ចាយលុយទេ។

កៈ ចាស!

ខៈ អត់ចាយលុយអត់ចាយមាសអត់ចាយអីទាំងអស់ តែលោកសង្ឃក៏ឱ្យសឹកចោលដើម្បីស្មើសិទ្ធ។

កៈ ចាស!

ខៈ ដល់ពេលអញ្ចឹងដើម្បីសម្ភារុធមានតែដូរស្រូវ។

កៈចាស! ហ្នឹងហើយ អញ្ចឹងបានជាយកអ្វីដែលជាភោគផល ទាំងអស់ទៅប្រទេសចិនដើម្បីយក។

ខៈ យកសម្ភារច្បាំងមក។

កៈ ហ្នឹងហើយ។

ខៈ បាទ!

កៈ អញ្ចឹងមួយៗឮគេថាត្រូវទេ គឺយកជញ្ជូនស្បៀងហ្នឹងទៅ នេះអស់ហើយទៅចិនអស់ហើយ។

ខៈ ទៅចិន។

កៈ អញ្ចឹងដោយសារដូរយកគ្រឿងសភារុធហ្នឹង បានមួយៗអត់មានអីហូបហ្នឹង។

ខៈ បាទៗ! គឺវាកាប់វាសម្លាប់ហើយវាបង្អត់ហ្នឹង ដើម្បីកុំឱ្យយើងហ្នឹងមានកម្លាំងដើម្បីតដៃវា។

កៈ អញ្ចឹងខ្ញុំឆ្ងល់ បើសិនវាធ្វើសង្គ្រាមអីហ្នឹង វាចង់ធ្វើសង្គ្រាមជាមួយអ្នកណាគេ ជាមួយតែប្រជាជនឯងសោះហ្នឹង។

ខៈ វាអញ្ចោះប៉ុលពតហ្នឹងវាស្អប់យួន។

កៈ ហ្អ៎! អញ្ចឹងដើម្បីបាញ់គ្នាជាមួយយួនអីចឹងទេហោ៎?

ខៈ បាទ! ដើម្បីជាមួយយួន ដល់ធ្វើទៅវាមិនបានឈ្នះយួន។

កៈ ហ៊ឺៗ!

ខៈ ហើយប៉ុនកាលហ្នឹងអញ្ចោះ សម្តេចនាយករដ្ឋមន្ត្រីយើងនឹងឃើញការស្លាប់ពីដើមហ្នឹង សម្តេចនាយករដ្ឋមន្ត្រីហ្នឹង។ ហ៊ឺ! នៅខាងខ្មែរក្រហមដែរ ដល់...

កៈ ពូនិយាយមកខ្ញុំយល់ច្រើនខ្លាំងមែនទែននេះហ៎។

ខ៖ បាទ!

ក៖ អញ្ចឹងនិយាយអញ្ចឹងទាំងអស់ហ្នឹង មកពួកគាត់ខាងក្រោយៗនឹងយល់អី ដឹងច្រើនណាស់ពូណា៎។

ខ៖ បាទ!

ក៖ ចាស!

ខ៖ ដល់ពេលសម្តេចនាយករដ្ឋមន្ត្រី យើងបច្ចុប្បន្នហ្នឹងរាជរដ្ឋាភិបាលហ្នឹងឃើញថាវាកាប់សម្លាប់ សូម្បីតែគាត់ក៏អត់បានជួបប្រពន្ធជួបកូនដែរ។ អញ្ចឹងគាត់ដាច់ចិត្តទៅពឹងវៀតណាមហ្នឹង។ បាទ! ទៅពឹងវៀតណាមទៅមកជួយវាយរំដោះយក កុំឱ្យប្រជាជនហ្នឹងស្លាប់ច្រើន។

ក៖ ចាស!

ខ៖ វាសន្យាប្រជុំអង្គការកំពូលៗវាថាជ័យឃោកម្ពុជា ពួកបូព៌ាសម្លាប់ឱ្យអស់កុំឱ្យសល់មួយ។

ក៖ តែសុទ្ធតែបងប្អូនជាតិសាសន៍ឯងសោះហ្នឹង។

ខ៖ បាទ! ដល់អានេះវាខ្លាំងជាងហ៊ីត្លែរទៅទៀត ហ៊ីត្លែរវា កាប់វាសម្លាប់មែន តែវាស្រឡាញ់ពូជសាសន៍វា។

ក៖ ចាស!

ខ៖ វាដើរកាប់សម្លាប់គេអ្នកដទៃ។

ក៖ ហ្នឹងហើយ។

ខ៖ ហើយនេះសាច់ឈាមខ្មែរដូចគ្នា។

ក៖ ហ្នឹងហើយ។ ពួកវាហ៊ីត្លែរពួកអាល្លឺម៉ង់តែ...

ខ៖ បាទ!

ក៖ តែវាកាប់សម្លាប់តែជនជាតិជ្វីបទេ ដល់ពេលខ្មែរយើងទៅកាប់សម្លាប់តែគ្នាឯង។

ខ៖ គ្នាឯងសូម្បីតែផ្ទះយើងហ្នឹងហ៊ិ មានកាំបិតមានពូថៅមានរណាអារ ឈើក៏វាដកអស់អត់ឱ្យទុកទេ តែកាលណាទុកខ្លាចយើងតបត។ វាកាប់វាសម្លាប់គ្មានឈប់គ្មានឈរទេ ដល់អញ្ចឹងបានជាកកើតកងទ័ពវៀតណាមមករំដោះនេះ។ បាទ!

ក៖ អញ្ចឹងមានសង្គ្រាមមួយសារទៀតខ្លាំងទៅ។

ខ៖ វាយយកមែនទែនម៉ងហ្នឹងហាំ។

ក៖ ពូពេលនៅជំនាន់ប៉ុលពត ពូមានតួនាទីអីនៅក្នុងហ្នឹងឬក៏ពូគ្រាន់ តែប្រជាជនធម្មតាធ្វើការធម្មតាទេ?

ខ៖ ខ្ញុំជាកងចល័តពិសេស កម្លាំងស្រួចរបស់កុមារ។

ក៖ ចាស!

ខ៖ ហើយវាធ្វើបាបដូចប្រពន្ធខ្ញុំបានលើកនិយាយអីចឹង។ សូម្បីបងជួបប្អូនក៏មិនបាន កូនជួបម៉ែជួបឪក៏មិនបានដែរ អត់ឱ្យជួបទាំងអស់វាបំបែកចេញទាំងអស់ ដល់អញ្ចឹងផលវិបាកឈឺចាប់ ខ្ញុំបងប្អូនជីដូនមួយខ្ញុំស្លាប់មិនតិចទេនៅអាពត។

ក៖ ចាស! ម៉េចដែរពូពេលការហូបចុកនៅពេលហ្នឹងម៉េចដែរពូ ហូបគ្រប់គ្រាន់អីដែរអត់?

ខ៖ អត់គ្រប់ទេ ព្រោះបបរចែកម្នាក់បានតែមួយវែកអាវែកសម្លយើងហ្នឹង។ អញ្ចឹងទេបោចតាំងពីត្រកួនត្រគៀតអីហ្នឹងបោចមកក្តិចយកមកហ្នឹងលាយទៅលាយអីចឹងហើយហូបទៅដល់វេទនាពេកទៅបងៗក៏ស្លាប់ច្រើនអីក៏អីទៅ សូម្បីតែក្មេងប៉ុនៗហ្នឹងហិ មានមណ្ឌលយកទៅដាក់។

ក៖ តូចៗមួយហ្នឹង?

ខ៖ ពេលម្តាយចេញពីធ្វើការឱ្យអ៊ឹមទៅ អ៊ឹមហើយត្រូវត្រឡប់មកផ្ទះហូបអាបបរមួយវែកម្នាក់ហ្នឹងហើយ ដល់ម៉ោងមួយចូលធ្វើការវិញ ដល់ម៉ោង៥ចេញ និយាយពីស្រូវងាកតែពីស្រូវតែម្តង យើងដាំដំឡូងយើងដាំពោតនៅជំនាន់ហ្នឹងណាំ តិចថាឱ្យយើងស៊ីអត់ឱ្យយើងស៊ីទេ តិចថាយើងតែយើងហ៊ានស៊ី គឺស្លាប់ហើយព្រោះយើងវាចោតថាអ្នកដែលហូបចុកហ្នឹងត្រូវយកទៅដាក់សម្ងហាភាព តែដូចជាដំឡូងដូចជាពោតយកទៅដាក់សម្ងហាភាព វាមិនបានយើងហូបវិញទេ តែគ្នាវាយកទៅស៊ីហើយ។

ក៖ ហើយយកបញ្ជូនទៅចិនដូរហ្នឹង។

ខ៖ អាអញ្ចឹងៗវាអត់បញ្ជូនទៅចិនទេ វាស៊ីមាត់វា។

ក៖ ហាំដល់ពេលច្រើនពេកវាស៊ីម៉េចអស់ទៅពូ?

ខ៖ វាផ្តល់ឱ្យទ័ពឱ្យកងទ័ពខ្មែរក្រហមហ្នឹង។

កៈ ហ៊្អឹ!

ខៈ វាយកទៅផ្តល់អីចឹងទៅ។

កៈ ចាស!

ខៈ ហើយពេលដែលពេលដែលវាជម្លៀស ប្រជាជនចេញស្ទើរតែគ្រប់ទីកន្លែងដែរ ដាំឱ្យទ័ពស៊ី ។

កៈ ចាស!

ខៈ ពោតទុកឱ្យទ័ពស៊ី វាបង្អត់តែប្រជាជនទេ កងទ័ពយូរៗប្រជាជនរក តែកន្ទួកលាយបបរអត់បានផង វេទនាហើយវាថាយួនវាយមិនឈ្នះយើងទេ។ យួនស៊ីកន្ទួកវាយអត់ឈ្នះទេ កុំភ័យអី យួនស៊ីកន្ទួក តែប្រជាពលរដ្ឋទេដែលរកកន្ទួកមិនបាន ដល់ថ្នាក់កាលពីសម័យមិនទាន់បាយរួមហ្នឹង បាយឯកជនខ្ញុំបីខាំស្រូវក្នុងមួយថ្ងៃ។

កៈ តិចមួយហ្នឹង។

ខៈ បាទ! ដល់យកស្រូវទៅបញ្ចេញទៅជាគ្រាប់អង្ករបានតែមួយកាំកន្លះទេ ហ្នឹងគឺស៊ីមួយថ្ងៃ។

កៈ ហើយមានបានរកអីគេក្រៅហូបអីទៀតទេពូ?

ខៈ កាលពីសម័យហ្នឹងនឹកថាហូបមិនកើតហូបមិនឆ្អែតដាច់ចិត្តលួច ដើរប្រហែលជាកន្លះគីឡូដីទៅក្រោយហ្នឹងទៅលួចឈ្លីស្រូវដាក់មកពីបីស្មុក ធ្វើស្មុកប៉ុនៗហ្នឹងកម្ពស់ៗហ្នឹងមួយពេញ។

កៈ ចុះបើវាឃើញម៉េចទៅពូ?

ខៈ បើឃើញគឺស្លាប់ទាំងពូជ ។

កៈ ហើយអញ្ចឹងលាក់ម៉េចទៅពូបើស្មុកប៉ុនៗណាណី?

ខៈ ចុះយើងចេញយប់ យប់ស្ងាត់។

កៈ ហ៊្អឹ!

ខៈ ទៅលូនសុទ្ធតែលូនអត់ហ៊ានដើរទេ ដើរខ្លាចគេឃើញអីចឹងមានតែលូនពីហ្នឹងទៅដីកន្លះគីឡូមួយគីឡូដីអីចឹងទៅ។

កៈ ហើយវាអត់ឃើញដែរពូណោះ?

ខៈ បាទ! ព្រោះយប់ងងឹតព្រោះនៅសម័យហ្នឹងមានប្រើអគ្គីសនីដូចយើងសម័យឥឡូវណា។

កៈ ងងឹតឆ្លុបគ្រប់កន្លែង។

ខៈ បាទ! រកតែប្រេងកាតអុជធ្វើចង្កៀងមិនបានផង។

កៈ ចាស!

ខៈ យកតែស្រូវមកដាក់ហាលលាយគ្នាទៅ អាស្រូវរបបហ្នឹង៣ខាំ ៣ខាំម្នាក់ហ្នឹងហា៎។

កៈ ចាស!

ខៈ ដាក់លាយគ្នាហើយហាលហើយយកទៅជាន់នឹងត្បាល់ជាន់ហ្នឹងទៅ។ បាទៗ ម៉ែខ្ញុំទៅទាក់យកអាកន្ទួកហ្នឹងយកច្រកបាវទុក អង្ករអីចឹងទៅទុកអញ្ចឹង ហ្នឹងបានអាបបរហ្នឹងគេហៅអាបបរឈ្មោលប៉ិៗហា៎ បានអាហ្នឹងហូបទៅ ហើយហូបគ្រប់គ្រាន់លួច។

កៈ បើមិនលួចគឺថាមិនបានអញ្ចឹងតែម្តង។

ខៈ បាទ!

កៈ ចាស!

ខៈ លួច!

កៈ ពូមានធ្លាប់ឃើញអ្នកណាត្រូវគេយកទៅសម្លាប់ចោលនៅមុខនឹងភ្នែកអីទេ?

ខៈ ឃើញ ឃើញនៅនឹងភ្នែកហ្នឹង វាយកទៅសម្លាប់ពេល
ពេលដែលកូនដែលយកទៅហ្នឹងដូចថាវាពេញកម្លោះដូចថាវាយកទៅសម្លាប់អីចឹងទៅណា៎ កូនស្រែកម៉ែអើយជួយកូនផងកូនលាហើយ វាវាយងាប់ហើយវាឱ្យអាកូនៗ ដើរស្រែកអាពាក្យហ្នឹងអាវាយកូនអាអ្នកវាយហ្នឹងហា៎។ ដើរស្រែកតាមហ្នឹងឱ្យយើងឈឺចាប់ឱ្យយើងតបតទៅនឹងអាលងាប់មួយទៀត ។

កៈ តែមួយៗចេះតែអត់ដែរពូហ៎?

ខៈ អត់ធ្មត់ យំក៏អត់បាន ឧទាហរណ៍ក្រុមគ្រួសារនាងស្លាប់ក៏នាងយំដែរ តែក្នុងសម័យនោះយំអត់បានទេ យំងាប់ទាំងពូជទៀត។

កៈ តែធ្វើអីសុទ្ធតែពូជម៉ងពូហ៎?

ខៈ បាទ! របស់យើងដូចថាដូចខ្ញុំនិយាយអីចឹងដូចថាដាំដំឡូង ហ៊ានគាស់មើមហ្នឹងស៊ីយើងខ្មាំងរបស់អង្គការហើយអញ្ចឹងគេត្រូវកម្ទេចហើយខ្មាំងហ្ន៎។ គេមិនទុកទេ ពោតក៏ដោយដំឡូង

ក៏ដោយចេកក៏ដោយហ៊ានតែស៊ីគឺក្បត់អង្គការ ព្រោះក្បត់សម្ភហាភាព តែដល់តែយកទៅដាក់នៅក្នុងសម្ភហាភាពហ្នឹងអង្គការវាលេបវាអត់ឱ្យយើងស៊ីទេ។

កៈ មួយៗសុទ្ធតែដឹង។

ខៈ ដឹង!

កៈ បើសិនជាតវ៉ាងាប់។

ខៈ ងាប់! ហើយហូបបបរអីចឹង ហ៊ី! បបរតែទឹកៗអីចឹងទៅ អង្ករមួយគ្រាប់មួយគ្រាប់ទៅ ហើយអាអង្គការគេឡើងឈរលើកៅអីស្រែកសួរកុមារកុមារឆ្ងាញ់ទេ? អាគ្នាឃ្លានចង់ងាប់ ហើយសួរអីចឹង ។

កៈ ឌឺម៉ង!

ខៈ បាទ! ឆ្ងាញ់ មានអាណាមួយថាមិនឆ្ងាញ់ទេ។

កៈ ថាមិនឆ្ងាញ់មើលងាប់បណ្ដោយ បើមិនឆ្ងាញ់ទេយប់ហ្នឹងបាត់ហើយ

ដល់មក៧៩(១៩៧៩)នេះ ខ្ញុំមានបាយហូបខ្ញុំមានត្រីដុតហូប។

កៈ ហ្នឹងពេញដូចថាទោះតែពិបាកម៉េចក៏ដោយ ក៏យើងអាចរកខ្លួនឯងហូបក៏បានដែរណោះ? មិនបាច់លួច។

ខៈ បាទ! ទៅរាវគ្រុំទៅរាវលៀសអី ដូចវាអត់មានអ្នកយកទៅចងយកទៅវាយចោលទេ។ បាទ!

កៈ ចាស!

ខៈ ចេះតែរស់ទៅ ។

កៈ អញ្ចឹងពូបន្ទាប់ពីថ្ងៃ ពូអាចនិយាយពីថ្ងៃចុងក្រោយនៃរបបប៉ុល ពតពេលថ្ងៃដែលយួនចូលមកវាម៉េចវិញទៅ?

ខៈ កាលពីយួនចូលមករំដោះប្រជាជនបានច្រើនប៉ុន្តែពួកខ្ញុំហ្នឹងត្រូវថ្ងៃ២៣ តុលា ត្រូវស្លាប់ទាំងអស់អត់មានឱ្យខ្មែររស់បានអីម្នាក់ទេ ដល់ពេលវៀតណាមដឹងផែនការស្រាប់អីចឹងវាយបង្ហំម៉ង វាយបង្ហំទាល់តែរត់ខ្វាត់ខ្វាយ លែងគិតពីរាស្ត្រលែងគិតពីប្រជាជនលែង គិតពីខ្លួនឯងអីចឹងទៅណាំ បានពួកខ្ញុំហ្នឹងរត់មួយយប់ទល់ភ្លឺបានទៅដល់យួន អត់ងងុយសុខចិត្តទ្រាំអត់ងងុយ។

កៈ ចូលដល់ព្រំដែនវាម៉ង?

ខៈ អត់ចូលដល់ព្រំដែនទេ ខ្ញុំរត់ចូលក្នុងមកយួនដែលរំដោះហ្នឹងហា៎ នេះ

នៅខេត្តពោធិ៍សាត់។

កៈ ចាស!

ខៈ រត់ចេះពីពោធិ៍សាត់ តែក៏នៅក្នុងពោធិ៍សាត់ដែរ។

កៈ ចាស!

ខៈ ចេញអត់ផុតពីពោធិ៍សាត់ទេ តែយួនចូលមកបានពាក់កណ្ដាលហើយ។

កៈ ចាស!

ខៈ រត់ចូលទៅហើយទៅហ្នឹងហើយតាំងពីម៉ោងថ្មើរហ្នឹងហិ ទល់គ្នាភ្លឺព្រលឹមឡើងម៉ង ម៉ោង៧

មើលគ្នាច្បាស់បានទៅដល់ តែបើវាតាមទាន់ក៏វាបាញ់សម្លាប់អស់ដែរ វាអត់ឱ្យរត់ចូលយួនទេ

កៈ សម្រេចចិត្តថាត្រូវតែរត់ម៉ងហោព្វ?

ខៈ បាទ! ត្រូវតែរត់។

កៈ បើមិនរត់ក៏ស្លាប់នៅក៏ស្លាប់មែនព្វ?

ខៈ នៅក៏ស្លាប់មិននៅក៏ស្លាប់ អញ្ចឹងអាមិននៅវាច្រើនជាងអាមិននៅ។

កៈ វាម៉េចវាគេចបានព្វណោះ?

ខៈ បាទ! ព្រោះនៅតំបន់ហ្នឹង នៅខេត្តពោធិ៍សាត់ហ្នឹងវាសម្បូរភ្នំហើយនិងព្រៃឈើ។

កៈ អញ្ចឹងអាព្វនបានហើយ។

ខៈ បាទ! អាចបាន!

កៈ អញ្ចឹងក៏បានរួចផុតពីជីវិតអញ្ចឹងទៅព្វណោះ?

ខៈ បាទ! បានផុតជីវិតហ្នឹង។

កៈ ពេលហ្នឹងដឹងថាម៉ែឪបងប្អូននៅឯណាឬក៏នៅជាមួយគ្នាដែរព្វ?

ខៈ ពេលដែលរត់ចូលយួនហ្នឹងគឺជុំគ្នាហើយ។

កៈ ហ្អ៎!

ខៈ សម្រេចចិត្តម៉ង។

កៈ ថាទោះបើស្លាប់រស់អីទៅម៉ង។

ខៈ បាទ! ម៉ែខ្ញុំគាត់ដាំបាយហាំអាឆ្នាំង ឆ្នាំងគេចាក់ អាឆ្នាំងគេចាក់ឌើរ៉ាប៉ុណ្ណឹង គាត់ដាំទាល់តែពេញ ហើយគាត់លើកបាយហ្នឹងរត់ទៅបណ្ដោយ ដាក់លើសង្រែករែកទៅហើយ រែកមួយយប់ទល់ភ្លឺ ភ្លឺដល់ម៉ោង៧ ៧ជាងបានទៅដល់វៀតណាម។

កៈ ហើយពេលហ្នឹងក៏បានរួចផុតទៅពូហេ៎?

ខៈ ផុតហើយ។

កៈ ពេលហ្នឹងវៀតណាមចូលមកពេញស្រុកយើងហើយហី?

ខៈ បាទ! ដល់រួចអញ្ចឹងឪពុកខ្ញុំគាត់ចេះ គាត់ចេះភាសាយួនហ្នឹងហាំ។

កៈ ចាស!

ខៈ គាត់បកប្រែត្រឹបៗៗៗ ហើយខ្ញុំផែងដែរអត់ដឹងថាឪពុកចេះយួនទេ ព្រោះគាត់រកស៊ីពីដើមជាមួយយួនហាំ ដល់អញ្ចឹងហើយគាត់ចេះយួន និយាយយួនថាកងទ័ពវៀតណាមថា កុំឱ្យពូទៅស្រុកអីឱ្យគាត់ធ្វើអាំងស៊ីប្រែតនេះហើយ ឪខ្ញុំនិយាយភាសាគ្នាគាត់ជាមួយគ្នាយួនហ្នឹងគាត់ថា ខ្ញុំបែកប្រពន្ធបែកកូនមកហើយ ខ្ញុំសូមទៅផ្ទះ វារំដោះមកបានរួចផុតថា វៀតណាមថាសូមឱ្យបងប្អូនប្រជាពលរដ្ឋ ទៅស្រុកតាម ទៅតាមរបស់រៀងៗខ្លួនទៅគ្រាន់តែមកដល់ស្រុកកំណើតស្រុកអ្នកលឿងហ្នឹង នាំគ្នាកោរ កោរក្បាលថ្វាយទាំងអស់។

កៈ កោរសក់ទាំងអស់គ្នាទៅ?

ខៈ កោរសក់ទាំងអស់គ្នា។

កៈ ហើយក៏រួចផុតបានជីវិតសុខសាន្តទាំងអស់គ្នាពេលហ្នឹងទៅពូណោះ?

ខៈ បាទ!

កៈ អញ្ចឹងពូបានចូលធ្វើទ័ពធ្វើអី ហើយរៀនតអីមកមានគ្រួសារអីមកអីចឹងពូណោះ?

ខៈ បាទៗ!

កៈ អញ្ចឹងពូសម្រាប់មួយជីវិតរបស់ពូគឺធ្លាប់ធ្វើទ័ពហើយធ្លាប់អីគេទៀតពូ?

ខៈ ធ្វើពេទ្យ។

កៈ ហើយមានធ្វើអីគេទៀតទេ?

ខ៖ បាទ! ការដែលបម្រើប្រទេសជាតិហ្នឹងមានតែប៉ុណ្ណឹង។

ក៖ ចាស! ហ្នឹងហើយ ការងារខាងក្រៅអីអត់មានរកអីទៀតណាពូហី?

ខ៖ អត់ទេ ពីព្រោះយើងរៀនពេទ្យហើយ។

ក៖ ចាស!

ខ៖ ដែលឈប់ពីកងទ័ពមកហើយមករៀនពេទ្យជំនាញ។

ក៖ ចាស!

ខ៖ ព្រោះនឹកឃើញថាយើងចំណេះដឹងប៉ុណ្ណឹងដែរយើងទៅរៀនទៅ ហោចណាស់ក៏បានសង្គ្រោះប្រពន្ធកូនដែរ។ បាទ! ខ្ញុំជួយសង្គ្រោះប្រពន្ធកូន។

ក៖ នៅធ្វើដល់ឥឡូវនៅធ្វើពេទ្យធ្វើអីដល់ឥឡូវល្អណាស់ គ្រួសារអត់សូវពិបាកចិត្តច្រើន។

ក៖ ខ្ញុំក៏វាខុសឆ្គង។

ខ៖ អញ្ចឹងលោកពូសម្រាប់ជីវិតរបស់លោកពូ ពេលវេលាណាដែលលោកពូពិបាកជាងគេនៅក្នុងជីវិតទៅ?

ខ៖ ពិបាកជាងគេបំផុតគឺក្នុងបច្ចុប្បន្ននេះ ។

ក៖ ដោយសារឈឺ។

ខ៖ ដោយសារខ្ញុំមានជម្ងឺ មានជម្ងឺបេះដូងរីកអីចឹងខ្ញុំពីដើម។ អរគុណណាស់ដែលអ្នកគ្រូបានមកយកសេចក្ដីសម្ភាស ផលស្រណុកផលវិបាករបស់ខ្ញុំដើម្បីកុនខ្មែរជំនាន់ក្រោយ។ បាទ!

ក៖ ចាស! ដើម្បីផលប្រយោជន៍ទាំងអស់គ្នានឹងណាំពូ។

ខ៖ បាទ! សូមថ្លែងអំណរគុណអ្នកគ្រូខ្លាំងមែនទែន ហើយអ្នកគ្រូមានអីចង់សួរទៀតសួរទៅ។

ក៖ ឥឡូវចុងក្រោយមានអីគេចង់ផ្ដែផ្ដាំកូន?

ខ៖ រឿងបណ្ដាំសុទ្ធឱ្យច្រើនណាស់មកហើយ តែសំខាន់គឺមានតែមួយគត់ ឱ្យកូនដាស់តឿនកូនឱ្យកូនខំរក។

ក៖ ចាស!

ខ៖ ទោះបីខ្ញុំវាយ៉ាងម៉េចវាមិនអីដែរណាំ អ្នកគ្រូណាំ កុំឱ្យតែកូនញ៉ុំខ្ញុំហ្នឹងវាដូចខ្ញុំទៅពឹងគ្នាមិនកើត ព្រោះឪពុកអីចឹងហើយបែរកូនមិនខំរកស៊ីតែស្រែកឱ្យឪពុកជួយ ឧទាហរណ៍

អីចឹងចុះតើឪពុកបានយកអីទៅជួយ ហើយថ្ងៃនេះអត់មានសូម្បីតែ សាច់ប៉ូវប៉ុនកូនដៃក៏អត់មានដែរ។ ចុះបើកូនអត់ជាងឪទៅទៀតតើកូនបានអីបានអីជួយ។

ក៖ ចាស!

ខ៖ អញ្ចឹងជួយកូនបានតែជាស់តឿនឱ្យកូនខំរក។ បាទ! ទោះបីថាមិនខ្ញុំឱ្យស៊ីទៅចុះក៏ខ្ញុំមិនតូចចិត្តនឹងវាសនារបស់ខ្ញុំដែរ ធ្វើម៉េចកូនត្រូវការចិញ្ចឹមប្តីប្រពន្ធវា តែសូមឱ្យតែខំរកទៅកុំឱ្យពិបាកដូចខ្ញុំអីចឹង មើលកាលទៅចាក់ទៅចាក់បេតុងហ្នឹងនៅអីខេត្តកំពត នៅស្អីភ្នំវល្លិ ភ្នំទាំងអស់ហ្នឹងក៏ជាភ្នំដែលខ្ញុំធ្លាប់ទៅបោសសម្អាតខ្មែរក្រហមដែរ។

ក៖ ហ្នឹងហើយពុល្បីថាភ្នំវល្លិហ្នឹងពួកខ្មែរក្រហមនៅហាំពូ។

ខ៖ នៅ ដល់ពេលអីចឹងដល់ពេលថៅកែគេអត់បើកលុយឱ្យអត់អីស៊ីចម្ការព្រៃចម្ការម្រេចហ្នឹងខ្ញុំនេះលក់អេតចាយនេះ ៩០,០០០ ៥០,០០០អីចឹងទៅខ្ញុំផ្តល់ឱ្យតាម វីន ស្អីអាស្អីទ្រូម៉ានីហ្នឹងឱ្យទៅកូនទៅឱ្យទៅទិញអង្ករចែកបងប្អូនហូបទៅ ។

ក៖ អញ្ចឹងពូ ពូឥឡូវមានកូននៅហ្នឹងទៀត?

ខ៖ មកទើបតែមកទេ នេះគេទើបតែមក មានប្តីប្រពន្ធគេទើបតែមកដល់ថ្ងៃហ្នឹងដែរ។

ក៖ មកពីភ្នំវល្លិហ្នឹងហេ៎?

ខ៖ មក មកពីភ្នំវល្លិហ្នឹងមកបានកន្លះខែហើយ ដល់ឥឡូវគេឡើងមកលេង អើរឃើញកូនប៉ុណ្ណឹងទៅកុំឱ្យវានឹកគ្នា តែមិនសុំកូនហូបឱ្យកូនមានហូបចុះ។

ក៖ ចាស! ពូមានអីចង់និយាយទៀតអត់?

ខ៖ នេះតែតាម សំណួររបស់អ្នកគ្រូគឺខ្ញុំឆ្លើយបានតែប៉ុណ្ណឹង។

ក៖ អញ្ចឹងអរគុណច្រើនលោកពូសម្រាប់ការសម្ភាសដ៏ក្បោះក្បាយនៅក្នុងថ្ងៃនេះ ហើយខ្ញុំដឹងថាការសម្ភាសមួយនេះគឺអើជីវប្រវត្តិដែលលោកពូបាននិយាយ  គឺថ្ងៃក្រោយពួកគាត់រៀនបានច្រើនណាស់លោកពូ។

ខ៖ បាទ!

កៈ ឱ្យដឹងថាជំនាន់យើងឥឡូវៗហ្នឹងហើយជំនាន់ដែលលោកពូបានកើតមកហ្នឹង ក្នុងអំឡុងឆ្នាំហ្នឹងតើជីវិតរបស់មនុស្សបានជួបរឿងអីគេខ្លះអីចឹងហា៎ តើការរស់នៅវាយ៉ាងម៉េចអីចឹងទេណា៎លោកពូ។

ខៈ បាទ!

កៈ អញ្ចឹងការសម្ភាសមិនមែនតែលោកពូម្នាក់ទេ គឺការសម្ភាសសម្រាប់ប្រជាជនខ្មែរទាំងអស់ទូទៅដែលគាត់មានអាយុ៣៥ឆ្នាំឡើងដើម្បីឱ្យគាត់អាចដឹងនិយាយពីបទពិសោធន៍ចែកចាយទៅថ្ងៃក្រោយអីចឹងទៅណា៎លោកពូ។

ខៈ បាទៗ!

កៈ អញ្ចឹងអរគុណច្រើន អញ្ចឹងអ្វីៗទាំងអស់ពួកគាត់នឹងបានស្ដាប់លោកពូ៕